ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

លេខ:.....៥៨៩.....ឧ
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ ៧៣៦
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ ៣៣៧
ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៤៥០
ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣

សាលក្រមព្រហ្មទណ្ឌ

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពត

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកំពត
កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ វេលាព្រឹក
ដែលមានសមាសភាពដូចតទៅ៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពត

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៣៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ ដែលមាន៖

ជនជាប់ចោទ៖

ឈ្មោះ [redacted] ញឹង ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិ៥ សង្កាត់៧ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ញ៉ាវ ។ ម្តាយឈ្មោះ [redacted] ម៉ុំ ។ ប្រពន្ធឈ្មោះ [redacted] សុគន្ធា ។ លែងលះ។ មានកូន ០១នាក់ ជាន៖តិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (គេចខ្លួន)

ត្រូវបានជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ឆក់ទូស៊ើ) ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈ្ញ ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងបញ្ជាក្តីឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណី៖

ឈ្មោះ [redacted] ពិសិដ្ឋ ភេទស្រី អាយុ ២៣ឆ្នាំ មានអាសយដ្ឋាននៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈ្ញ ខេត្តកំពត។

Scanned with CamScanner
Scanned with CamScanner

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៨៧១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត។

-បានឃើញ ដីកាដំណោះស្រាយលេខ ១១៨៩ ក្រ.ទ/២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត។

-បានឃើញ ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៩៤២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៣ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពត។

អង្គហេតុដែលថ្កើងមកតុលាការ

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៧ និង៣០ នាទី មានករណី លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ឆក់ទូរស័ព្ទ) មួយកើតឡើងនៅចំណុចភូមិត្រពាំងជ្រៃ ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ញ៉ឹង ភេទប្រុស អាយុ ៣៣ឆ្នាំ បានធ្វើសកម្មភាពទូរស័ព្ទរបស់ជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ ភេទស្រី អាយុ ២២ឆ្នាំ បណ្តាលឱ្យបាត់បង់ទូរស័ព្ទចំនួន ១គ្រឿងម៉ាក OPPO A83 ពណ៌ទឹកមាស។

ឧាហរណ៍សង្ខេបការ

- ខ្លឹមសារសង្ខេបនៃអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ញ៉ឹង នៅមន្ត្រីនគរបាលយុត្តិធម៌៖ បានឆ្លើយថា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ម៉ោងប្រហែលជា ៥ និង ២០ នាទី ខ្លួនបានជិះម៉ូតូចេញពីធ្វើការសំណង់នៅជិតផ្សារលានស្រូវ ក៏បានជួបឈ្មោះ [redacted] ពិសិដ្ឋ។ ពេលនោះខ្លួនក៏បាននិយាយគ្នារឿងឆាតតាមទូរស័ព្ទទៅរកមិនព្រមលើក និងឆ្លើយតប។ ឈ្មោះ [redacted] ពិសិដ្ឋ និយាយថាជាប់រវល់ ខ្លួនក៏សង្ស័យថា ពិសិដ្ឋ មានអ្នកផ្សេង ខ្លួនសុំទូរស័ព្ទមកមើល។ បន្ទាប់មកគាត់ឈប់ម៉ូតូនៅផ្លូវគ្រួសក្រហមជិតដល់ផ្ទះគាត់ ហើយបានហុចទូរស័ព្ទឱ្យខ្លួនគាត់ក៏ជិះម៉ូតូទៅបាត់។ ក្រោយមកគេយកទូរស័ព្ទ ១ គ្រឿងទៀត ឆាតចូលមកក្នុងទូរស័ព្ទដែលខ្លួនយកមក ហើយខ្លួនក៏ឆាតទៅវិញថា "មកយកទូរស័ព្ទវិញ" តែគាត់ឆ្លើយថា "រត់យកវិញទេ" ខ្លួនក៏យកទូរស័ព្ទនោះទៅទុកនៅផ្ទះរយៈពេល ២យប់។ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ខ្លួនឮថាឈ្មោះ [redacted] ពិសិដ្ឋ បានប្តឹងខ្លួនទៅសមត្ថកិច្ចឃុំត្រពាំងធំ ហើយខ្លួនក៏យកទូរស័ព្ទនោះទៅឱ្យប្អូនប្រុសខ្លួនឈ្មោះ [redacted] ពៅ និង ឈ្មោះ សៀន យកទៅប្រគល់ជូនសមត្ថកិច្ចឃុំត្រពាំងធំ តែគេមិនយក។ សូមបញ្ជាក់ថា រវាងខ្លួន និងឈ្មោះ ពិសិដ្ឋ មានទំនាក់ទំនងស្រលាញ់គ្នាជាង ១ឆ្នាំហើយ និងបានដើរលេងនៅកែវ ទឹកឈូ ជាញឹកញាប់ ព្រមទាំងធ្លាប់ចេញចូលផ្ទះរបស់គាត់ ជាហូរហែរដែរ។ ម្យ៉ាងទៀត ខ្លួនក៏ធ្លាប់ធ្វើទ្រុងមាន់ និង ទិញមាន់ទុកឱ្យចិញ្ចឹមទៀតផង។

- ខ្លឹមសារសង្ខេបនៃអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ៖ បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted] ញ៉ឹង ព្រោះគាត់ធ្លាប់ជាសង្សារនឹងខ្លួន តែខ្លួនបានផ្តាច់ទំនាក់ទំនងជាមួយគ្នាប្រហែលជា ៨ ទៅ ៩ ថ្ងៃ មុនថ្ងៃកើតហេតុ។ កាលពីថ្ងៃខែមិនចាំឆ្នាំ២០២០ វេលាម៉ោង ៥ ល្ងាច ខ្លួនចេញពីធ្វើការនៅសាលាឃុំ ជិតសណ្ឋាគារឌីយ៉ាម៉ង់ ខ្លួនបានចូលផ្សារប្រហែលវេលាម៉ោង ហើយក៏បានជិះម៉ូតូត្រឡប់ទៅផ្ទះម្នាក់ឯង ដោយជិះតាមផ្លូវជាតិលេខ៣ ស្រាប់តែឈ្មោះ [redacted] ញ៉ឹង ជិះម៉ូតូម្នាក់ឯងដែរតាមពីក្រោយ ទៅផ្លូវបំបែកវាងក្រុង ហើយឈប់ពីមុខម៉ូតូខ្លួន។ ពេលនោះខ្លួន

Scanned with CamScanner

Scanned with CamScanner

ក៏បានឈប់ម៉ូតូដែរ បន្ទាប់មកគាត់បានចុះពីលើម៉ូតូហើយនិយាយថា មកយកទូរស័ព្ទ បើមិនឱ្យគាត មិនឱ្យខ្លួនទៅផ្ទះទេ ហើយគាត់ស្ទុះយកទូរស័ព្ទក្នុងកាបូបខ្លួន រួចហើយជិះម៉ូតូចេញទៅបាត់។ ពេលនោះខ្លួនមិនហ៊ានស្រែកទេ ព្រោះទីនោះស្ងាត់។ លុះស្អែកឡើង ទើបខ្លួនទៅប្តឹងសមត្ថកិច្ច។ ទូរស័ព្ទខ្លួនម៉ាក OPPO ពណ៌ផ្កាឈូ។ ក្នុងរឿងនេះ ខ្លួនសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសុំឱ្យឈ្មោះ [redacted] ត្បឹង ប្រគល់ទូរស័ព្ទមកឱ្យខ្លួនវិញ។

- **ខ្លឹមសារសង្ខេបនៃចម្លើយបំភ្លឺសាក្សីសមត្ថកិច្ចឈ្មោ[redacted] ចាន់ណា នាយការិយាស្តីទី៖** បានឆ្លើយបំភ្លឺថា ក្នុងរឿងនេះ ពិដំបូងជនជាប់ចោទ និង ជនរងគ្រោះ ជាសង្សារនឹងគ្នា។ នៅថ្ងៃកើតហេតុ ជនជាប់ចោទ បានទៅតាមយកទូរស័ព្ទដើម្បីឆែកមើល តែជនរងគ្រោះពុំព្រមឱ្យ ហើយជនជាប់ចោទ នៅតែតាមយកទាល់តែបាន ដោយគ្មានការអនុញ្ញាតពីជនរងគ្រោះឡើយ។ ខ្លួនពុំបានសួរពាក់ព័ន្ធថា ទូរស័ព្ទនេះ ជារបស់អ្នកណានោះទេ។

-**ខ្លឹមសារសង្ខេបនៃសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖** ផ្អែកតាមរបាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការ ឃើញថា ជនជាប់ចោទបានគេវេស ពុំបានចូលបង្ហាញខ្លួនគ្រប់នីតិវិធីឡើយ។ ហេតុនេះ តំណាងអយ្យការ យល់ឃើញថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងបញ្ជាក្តីឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ច្បាប់ដដែន។ ស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមនីតិវិធីច្បាប់ និង ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។

-**ខ្លឹមសារសង្ខេបនៃសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖** ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និង ពិនិត្យកសុំតាងក្នុងសំណុំរឿងរួចមក ឃើញថា កូនក្តីខ្លួន និង ដើមបណ្តឹងរដ្ឋប្បវេណីជាសង្សារនឹងគ្នា គឺពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថា កូនក្តីខ្លួនលួចយកទូរស័ព្ទរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ម្យ៉ាងទៀត កូនក្តីខ្លួនយកទៅនេះ ពុំមានចេតនាយកមកធ្វើជារបស់ខ្លួនដែរ និងយកទៅលក់ដូរដើម្បីបានផលប្រយោជន៍អ្វីដែរ គឺគ្រាន់តែយកទៅឆែកមើលតែប៉ុណ្ណោះ ហើយទូរស័ព្ទនេះ កូនក្តីខ្លួនក៏មានបំណងយកទៅប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណីដែរ តែដើមបណ្តឹងរដ្ឋប្បវេណី ពុំព្រមទទួលយកវិញ។ ហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានធ្វើមូលវិចារណ៍ ពិនិត្យកសុំតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner
Scanned with CamScanner

សំអាងហេតុ

១-ផ្អែកតាមដីកាដំណោះស្រាយលេខ ១១៨៥ ព្រ.ទ/២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត បានសម្រេចបញ្ជូន បុគ្គល និងអង្គហេតុមក សាលាដំបូងខេត្តកំពត ដើម្បីជំនុំជម្រះ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត អំពើហិង្សា (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ញ៉ឹង ដែលក្រុមប្រឹក្សាជំនុំជម្រះ អាចលើកយកបកបើកសវនាការជំនុំជម្រះបាន ដោយយោងតាមបញ្ញត្តិមាត្រា ២៩១ មាត្រា ៣៩៨ និងមាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ញ៉ឹង នាពេលសវនាការ បានឆ្លើយថា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ម៉ោងប្រហែលជា ៥ និង ២០ នាទី ជនជាប់ចោទ បានជិះម៉ូតូចេញពីធ្វើការសំណង់នៅជិតផ្សារលាននស្រូវ កំបានជួបឈ្មោះ [redacted] ពិសិដ្ឋ។ ពេលនោះ ខ្លួនកំបាននិយាយគ្នារឿងឆាតតាមទូរស័ព្ទទៅរកមិនព្រមលើកនិងឆ្លើយតប។ ឈ្មោះ [redacted] ពិសិដ្ឋ និយាយថា ជាប់វល់ ខ្លួនក៏សង្ស័យថា ពិសិដ្ឋ មានអ្នកផ្សេង ខ្លួនសុំទូរស័ព្ទមកមើល។ បន្ទាប់មក គាត់ឈប់ម៉ូតូនៅផ្លូវគ្រួសក្រហមជិតដល់ផ្ទះគាត់ ហើយបានហុចទូរស័ព្ទឱ្យខ្លួន គាត់ក៏ជិះម៉ូតូទៅបាត់។ ក្រោយមកគេយកទូរស័ព្ទ ១ គ្រឿងទៀត ឆាតចូលមកក្នុងទូរស័ព្ទដែលខ្លួនយកមក ហើយខ្លួនក៏ឆាតទៅវិញថា មកយកទូរស័ទ្ធវិញ តែគាត់ឆ្លើយថា អត់យកវិញទេ ខ្លួនក៏យកទូរស័ព្ទ នោះទៅទុកនៅផ្ទះរយៈពេល ២ យប់។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយបំភ្លឺថា នៅថ្ងៃកើតហេតុ ខ្លួនចេញពីធ្វើការនៅសាលាឃុំ ជិតសណ្ឋាគារឌីហ៊ាម៉ង់ និង បានចូលផ្សារប្រហែលកន្លះម៉ោង ហើយក៏បានជិះម៉ូតូត្រឡប់ទៅផ្ទះម្នាក់ឯង ស្រាប់តែឈ្មោះ [redacted] ញ៉ឹង ជិះម៉ូតូម្នាក់ឯងតាមពីក្រោយ ទៅផ្លូវបំបែកវាងក្រុង ហើយឈប់ពីមុខម៉ូតូខ្លួន។ ពេលនោះខ្លួនក៏បានឈប់ម៉ូតូដែរ បន្ទាប់មកវាក៏បានចុះពីលើម៉ូតូហើយនិយាយថា មកយកទូរស័ព្ទ បើមិនឱ្យ វាមិនឱ្យខ្លួនទៅផ្ទះទេ ហើយវាក៏លួកយកទូរស័ព្ទក្នុងកាបូបខ្លួន រួចហើយជិះម៉ូតូចេញទៅបាត់។ ផ្អែកតាម **មាត្រា ៣៥៣** នៃក្រមព្រហ្មទណ្ឌចែងថា *"អំពើលួចគឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកជាកម្មសិទ្ធិរបស់ខ្លួន"*។ **មាត្រា ៣៥៧** (ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា) ចែងថា *"អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ : ១-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ"*។ ការណ៍នេះ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា តាមអំណានចម្លើយជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ឃើញជនជាប់ចោទ បានយកទូរស័ព្ទពីដើមបណ្តឹងរដ្ឋប្បវេណីដោយពុំមានការអនុញ្ញាត ហើយក៏ជិះចេញទៅដោយពុំបានប្រព្រឹត្តអំពើហិង្សាទៅលើដើមបណ្តឹងរដ្ឋប្បវេណីឡើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមានរងរបួសស្នាមអ្វីឡើយ។ ហេតុនេះ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា សកម្មភាពរបស់ជនជាប់ចោទជាបទ លួច ពុំមែនជាបទ លួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា នោះទេ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចប្តូរបទចោទពីបទ លួចមានស្ថានទម្ងន់ដោយសារការប្រព្រឹត្តអំពើហិង្សា មានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង

Scanned with CamScanner

Scanned with CamScanner

Scanned with CamScanner

មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មក បទ ល្មច ហានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣-យល់ឃើញថា អំពើរបស់ជនជាប់ចោទ បង្ហាញឱ្យឃើញពីចេតនាទុច្ចរិតក្នុងការដកហូតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ដើម្បីជាប្រយោជន៍ខ្លួនឯង ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសង្គម និង ធ្វើឱ្យបាត់បង់ទ្រព្យសម្បត្តិអ្នកដទៃ។

៤-យល់ឃើញថា ជនជាប់ចោទ ជានិតិជនមាននីតិសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជនជាប់ចោទមានបញ្ហាវិបល្លាសការីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ។ ជនជាប់ចោទមានវិចារណញ្ញាណ គ្រប់គ្រាន់ក្នុងការយល់ដឹងអំពីសកម្មភាពរបស់ខ្លួន។

៥-យល់ឃើញថា មានភស្តុតាង និងគាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដើម្បីប្រកាសពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ញ៉ឹង ពីបទ ល្មច ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៦-យល់ឃើញថា តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការ ដែលបានលើកឡើងអំពីអង្គហេតុ និងអង្គច្បាប់ ព្រមទាំងភស្តុតាងដាក់បន្ទុកមួយចំនួនលើជនជាប់ចោទខាងលើ ស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និង ចេញដីបង្គាប់ឱ្យចាប់ខ្លួន គប្បីតុលាការពិចារណា និងសម្រេចដោយផ្អែកតាមអង្គហេតុ និងអង្គច្បាប់។

៧-យល់ឃើញថា តាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាការស្នើសុំនេះ ពុំមានភស្តុតាងណាមួយមកបញ្ជាក់ ឬ បង្ហាញ អាចឱ្យតុលាការលើកយកមកពិចារណាបានឡើយ គប្បីតុលាការពុំលើកយកការស្នើសុំនេះមកពិចារណាឡើយ។

៨-យល់ឃើញថា បទល្មើសដែលជនជាប់ចោទ ជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ដើម្បីយកមកធ្វើជារបស់ខ្លួន ហើយសកម្មភាពនេះទ្វីតែជនរងគ្រោះពុំមានរបួសអ្វីពិតមែន តែសកម្មភាពរបស់ជនជាប់ចោទ បង្កឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសង្គម និង ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ និង ពិន័យជាប្រាក់ក្នុងកម្រិតលើសពីអប្បបរមា ដោយឈរលើគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍ឯកត្តកម្មនៃទោស តាមបញ្ញត្តិមាត្រា ២៨ មាត្រា ៥៦ និង មាត្រា ៥៧ នៃក្រមព្រហ្មទណ្ឌ ដើម្បីជាការព្រមាន អប់រំ និងកែប្រែជនជាប់ចោទកុំឱ្យប្រព្រឹត្តអំពើខាងលើសារជាថ្មី។

៩-យល់ឃើញថា ដើម្បីធានារក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ គប្បីតុលាការបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ញ៉ឹង ដើម្បីយកមកអនុវត្តទោសយោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០-យល់ឃើញថា ក្នុងរឿងនេះ ដើមបណ្តឹងរដ្ឋប្បវេណី បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដោយសុំទាមទារទូរស័ព្ទម៉ាក OPPO ពណ៌ផ្កាឈូក ចំនួន ១គ្រឿងវិញ គប្បីតុលាការសម្រេច ដោយផ្អែកការខូចខាតជាក់ស្តែង។

Scanned with CamScanner

សេចក្តីសម្រេច

ហេតុដូច្នេះ សាលាដំបូងខេត្តកំពត សម្រេច

១-ផ្តន្ទរបទចោទលើជនជាប់ចោទឈ្មោះ [redacted] ញឹង ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកបទលួច តាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-ប្រកាសថាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ញឹង ពីបទ លួច ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈ្ង ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង បញ្ជាក្តីឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣-ផ្តន្ទរទោសលើជនជាប់ចោទឈ្មោះ [redacted] ញឹង ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ពីបទ លួច ប្រព្រឹត្តនៅភូមិត្រពាំងជ្រៃ ឃុំត្រពាំងជ្រៃ ស្រុកទឹកឈ្ង ខេត្តកំពត កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង បញ្ជាក្តីឱ្យផ្តន្ទាទោសតាម មាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោ [redacted] ញឹង (មានអត្តសញ្ញាណដូចខាងលើ)។

៥-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ញឹង សងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ចំនួន ២០០.០០០ (ពីរសែន) រៀល។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ កំចាំងមុខជនជាប់ចោទឈ្មោះ [redacted] ញឹង និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ។

លើកផ្លូវប្តឹងទាស់ ឬ/និង ឧទ្ធរណ៍តាមកំណត់ច្បាប់។

ចៅក្រមប្រឹក្សា	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រាឈ្មោះ [redacted]		
ក្រឡាបញ្ជីសវនាការ		
ហត្ថលេខា និងត្រាឈ្មោះ [redacted]		

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានផតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំឆោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅកំពត,ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

Scanned with CamScanner